## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ៣៨ អនក្រ.បក

### ស្តីពី

### ការបង្កើតឃុំតាសាញចំណុះស្រុកសំឡូត ខេត្តបាត់ដំបង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១.-** ត្រូវបានបង្កើតឃុំតាសាញ ចំណុះស្រុកសំឡូត ខេត្តបាត់ដំបង ដោយកាត់យកពីភូមិសាស្ត្រ ឃុំ ស៊ុងស្រុកសំឡូត ខេត្តបាត់ដំបង ។

**មាត្រា ២.-** ឃុំ តាសាញ មានព្រំប្រទល់រដ្ឋបាលដូចខាងក្រោមៈ

- ខាងជើងទល់នឹង ឃុំ អូរសោម និង ឃុំ មានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង
- ខាងត្បូងទល់នឹង ឃុំ ស៊ុង នឹង ឃុំ កំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង
- ខាងកើតទល់នឹង ឃុំ កំពង់ល្ពៅ នឹង ឃុំ អូរសោម ស្រុកសំឡូត ខេត្តបាត់ដំបង
- ខាងលិចទល់នឹង ឃុំ ស៊ុង នឹង ឃុំ មានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង

**មាត្រា ៣.-** ទីតាំងរដ្ឋបាលសាលាឃុំ តាសាញ ស្ថិតក្នុងភូមិអូរស្នូត ។

**មាត្រា ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៣៩ អនក្រ.បក
## ស្តីពី
## ការបង្កើតឃុំតាគ្រី
## ចំណុះស្រុកកំរៀង ខេត្តបាត់ដំបង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១.-** ត្រូវបានបង្កើតឃុំតាគ្រី ចំណុះស្រុកកំរៀង ខេត្តបាត់ដំបង ដោយកាត់យកពីភូមិសាស្ត្រ ឃុំអូរដា ឃុំតាសែន នឹងឃុំត្រាង នៃស្រុកកំរៀង ខេត្តបាត់ដំបង ។

**មាត្រា២.-** ឃុំ តាគ្រី មានព្រំប្រទល់រដ្ឋបាលដូចខាងក្រោម:

- ខាងកើតទល់នឹង ស្រុកបវេល ខេត្តបាត់ដំបង
- ខាងលិចទល់នឹង ឃុំ អូដារ ឃុំ តាសែន ឃុំ ត្រាង នឹង ឃុំ កំរៀង ស្រុក កំរៀង ខេត្តបាត់ដំបង